# តើអ្នកចង់ចុះឈ្មោះបោះឆ្នោតដែរឬទេ?

ដើម្បីចុះឈ្មោះបោះឆ្នោតក្នុងរដ្ឋ CALIFORNIA, អ្នកត្រូវតែ៖

1. ត្រូវតែជាពលរដ្ឋនៃសហរដ្ឋអាមេរិក;
2. ត្រូវតែរស់នៅក្នុងរដ្ឋ California;
3. ត្រូវតែមានអាយុយ៉ាងតិច 18 ឆ្នាំ ត្រឹមថ្ងៃបោះឆ្នោតលើកក្រោយ ហើយ
4. អ្នកមិនអាចកំពុងសជាប់ក្នុងពន្ធនាគាររដ្ឋ ឬរដ្ឋសហព័ន្ធ ឬកំពុងត្រូវបានដោះលែង ក្រោមលក្ខខណ្ឌ ចំពោះការផ្តន្ទាទោសបទឧក្រិដ្ឋ និង បច្ចុប្បន្ន មិនត្រូវបានរកឃើញដោយតុលាការថា គ្មានសមត្ថភាពផ្លូវចិត្តដើម្បីបោះឆ្នោតឡើយ។

**សេចក្តីព្រមាន៖** តាមច្បាប់រដ្ឋ និងច្បាប់រដ្ឋសហព័ន្ធ បើអ្នកដឹងថា អ្នកគ្មានសិទ្ធិបោះឆ្នោតទេ តែអ្នកដាក់សេចក្តីប្រកាសចុះឈ្មោះបោះឆ្នោត នោះគឺជាបទល្មើស។

## សេចក្តីជូនដំណឹងសំខាន់ៗ

1. ការដាក់ពាក្យចុះឈ្មោះ ឬការបដិសេធមិនចុះឈ្មោះបោះឆ្នោត នឹងមិនប៉ះពាល់ដល់ចំនួនជំនួយ ដែលទីភ្នាក់ងារនឹងត្រូវផ្តល់ជូនអ្នកឡើយ។
2. បើអ្នកចង់បានជំនួយ ក្នុងការបំពេញពាក្យសុំចុះឈ្មោះបោះឆ្នោត យើងនឹងជួយដល់អ្នក។ សេចក្តីសម្រេចថាតើ ត្រូវស្វែងរក ឬទទួលយកជំនួយ គឺជាការសម្រេចចិត្តរបស់អ្នក។ អ្នកអាចបំពេញពាក្យសុំដោយខ្លួនឯងបាន។
3. បើអ្នកជឿជាក់ថា មានអ្នកណាបានជ្រៀតជ្រែកលើសិទ្ធិចុះឈ្មោះ ឬសិទ្ធិបដិសេធមិនចុះឈ្មោះបោះឆ្នោតរបស់អ្នក សិទ្ធិឯកជនក្នុងការសម្រេចថាតើ ត្រូវចុះឈ្មោះ ឬដាក់ពាក្យសុំចុះឈ្មោះបោះឆ្នោត ឬសិទ្ធិជ្រើសរើសគណបក្សនយោបាយរបស់ខ្លួន ឬនិន្នាការនយោបាយផ្សេងទៀត អ្នកអាចដាក់ពាក្យបណ្តឹងមករដ្ឋមន្ត្រី ដោយហៅទូរស័ព្ទឥតគិតថ្លៃមកលេខ 800-345-VOTE ឬសរសេរមក៖ Secretary of State, 1500 11th Street, Sacramento, CA 95814.
4. បើអ្នកផ្លាស់លំនៅទៅអាសយដ្ឋានថ្មី ឬបើអ្នកផ្លាស់ប្តូរឈ្មោះ ឬគណបក្សនយោបាយ អ្នកត្រូវតែបំពេញពាក្យចុះឈ្មោះអ្នកបោះឆ្នោតថ្មី។
5. ការចុះឈ្មោះបោះឆ្នោតជាមុន មានសម្រាប់អ្នកអាយុ 16 & 17 ឆ្នាំ ដែលមានសិទ្ធិចុះឈ្មោះ ដោយចូលទៅ RegisterToVote.ca.gov ឬបំពេញពាក្យចុះឈ្មោះអ្នកបោះឆ្នោតជាក្រដាស។ ចំពោះយុវជនរដ្ឋ California ដែលបានចុះឈ្មោះបោះឆ្នោតជាមុន ការចុះឈ្មោះរបស់គេនឹងមានប្រសិទ្ធិភាពពេលគេដល់អាយុ 18 ឆ្នាំ។

## តើអ្នកចង់ចុះឈ្មោះបោះឆ្នោតនៅទីនេះ ថ្ងៃនេះដែរឬទេ?
(សូមគូសយកចម្លើយមួយ)

☐ ខ្ញុំបានចុះឈ្មោះបោះឆ្នោតរួចហើយ នៅអាសយដ្ឋានបច្ចុប្បន្នរបស់ខ្ញុំ ឬខ្ញុំមិនមានសិទ្ធិចុះឈ្មោះបោះឆ្នោតទេ និងខ្ញុំមិនត្រូវពាក្យសុំដើម្បីចុះឈ្មោះបោះឆ្នោតទេ។

☐ បាទ/ចាស៎ ខ្ញុំចង់ចុះឈ្មោះបោះឆ្នោត។
(សូមបំពេញទម្រង់ដែលភ្ជាប់មកជាមួយ ឬចូលទៅ http://www.registertovote.ca.gov/ ដើម្បីចុះឈ្មោះអនឡាញ)

☐ ទេ ខ្ញុំមិនចង់ចុះឈ្មោះបោះឆ្នោតទេ។

(សម្គាល់៖ បើអ្នកមិនគូសយកប្រអប់ណាមួយទេ គេនឹងចាត់ទុកថា អ្នកបានសម្រេចចិត្តមិនចុះឈ្មោះបោះឆ្នោត នៅពេលនេះទេ។)

**សូមសរសេរឈ្មោះរបស់អ្នកជាអក្សរពុម្ពត្រង់នេះ៖** ______________________________

ទម្រង់ពាក្យនេះ នឹងត្រូវរក្សាទុកនៅទីភ្នាក់ងារ។

**(For Agency Use Only)**

**Case No.** ____________________ **Case Name** ________________________________

**Voter registration form completed:** **Yes** _____ **No** _____

**Voter registration form given:** **Yes** _____ **No** _____

**Employee Initials:** ____________ **Worker No.** __________ **Date:** __________

**Form 50-110 (REV 10/2019)**